# ត្រៀមខ្លួន. បន្តការធានារ៉ាប់រង.

សូមចូលមើល www.staycovered.ri.gov ដើម្បីស្វែងយល់បន្ថែមអំពីការបន្តរបស់ Medicaid និងស្វែងរកជំនួយ។

យើងកំពុងសរសេរព័ត៌មានសំខាន់ៗអំពីអត្ថប្រយោជន៍សុខភាព Medicaid របស់អ្នក។ នៅថ្ងៃទី 1 ខែមេសា ការបន្តសិទ្ធិទទួលបាន Medicaid ប្រចាំឆ្នាំនឹងបន្ត។ ការបន្តជួយយើងខ្ញុំក្នុងការបញ្ជាក់ថា អ្នករាល់គ្នាដែលមាន Medicaid នៅតែមានសិទ្ធិទទួលបាន។

យើងបានបញ្ឈប់ការបន្តប្រចាំឆ្នាំ ដើម្បីជួយធ្វើឱ្យអ្វីៗកាន់តែងាយស្រួលក្នុងអំឡុងគ្រាមានអាសន្នផ្នែកសុខភាពសាធារណៈរបស់សហព័ន្ធ COVID-19។ ឥឡូវនេះ រដ្ឋាភិបាលសហព័ន្ធកំពុងតម្រូវឱ្យយើងខ្ញុំចាប់ផ្ដើមដំណើរការម្ដងទៀត។ អ្នកនឹងទទួលបានដំណឹងពីយើងខ្ញុំអំពីការធានារ៉ាប់រងរបស់អ្នកនៅពេលណាមួយនៅចន្លោះពីថ្ងៃទី 1 ខែមេសា ឆ្នាំ 2023 ដល់ថ្ងៃទី 31 ខែមីនា ឆ្នាំ 2024។ វាជារឿងសំខាន់ដែលយើងដឹងពីរបៀបទាក់ទងអ្នក ដូច្នេះយើងអាចជូនដំណឹងដល់អ្នកក្នុងអំឡុងពេលនៃដំណើរការនេះ។

## អ្វីដែលអ្នកត្រូវធ្វើនៅថ្ងៃនេះ

ត្រូវប្រាកដថាព័ត៌មានទំនាក់ទំនងរបស់អ្នកត្រឹមត្រូវ។ នេះគឺជារបៀប៖

1. តាមរយៈកុំព្យូទ័រ ឬទូរសព្ទស្មាតហ្វូន៖
   - សូមចូលមើល www.healthyrhode.ri.gov ឬទាញយកកម្មវិធីទូរសព្ទចល័តរបស់ HealthyRhode ហើយឡុកចូល។
   - ចុច "My Profile" (ប្រវត្តិរូបរបស់ខ្ញុំ)។ បន្ទាប់មកចុច "My Contact Information" (ព័ត៌មានទំនាក់ទំនងរបស់ខ្ញុំ)
   - ពិនិត្យមើលឈ្មោះ អាសយដ្ឋានប្រៃសណីយ៍ លេខទូរសព្ទ និងអាសយដ្ឋានអ៊ីមែលរបស់អ្នក។ រក្សាទុករាល់ការផ្លាស់ប្ដូរ។
   - ចុះឈ្មោះសម្រាប់សារជាអក្សរអំពីការធានារ៉ាប់រងរបស់អ្នក។ ចុច "My Contact Information" (ព័ត៌មានទំនាក់ទំនងរបស់ខ្ញុំ) ហើយពិនិត្យមើល "Sign Up for Text Messages." (ចុះឈ្មោះសម្រាប់សារជាអក្សរ)។
2. តាមរយៈទូរសព្ទ៖
   - ទូរសព្ទទៅលេខនៅលើបណ្ណធានារ៉ាប់រងរបស់អ្នក ប្រសិនបើអ្នកមានគម្រោង Neighborhood Health Plan of Rhode Island គម្រោង Tufts Health Plan (RITogether) ឬគម្រោង UnitedHealthcare Community Plan (UHCCP)។ ឬទូរសព្ទទៅ HealthSource RI (HSRI) ពីម៉ោង 8 ព្រឹក ដល់ម៉ោង 6 ល្ងាច ថ្ងៃធ្វើការ តាមរយៈលេខ 1-855-840-4774។

## អ្វីដែលអ្នកគួរធ្វើដើម្បីការពារព័ត៌មានរបស់អ្នក

ប្រសិនបើអ្នកទទួលបានការហៅទូរសព្ទ ឬលិខិតដែលទំនងជាមិនត្រឹមត្រូវ ចូរទាក់ទងអង្គភាពផ្នែកការក្លែងបន្លំតាមរយៈលេខ (401) 574-8175 ឬចូលមើល www.omb.ri.gov/internal-audit/fraud-hotline ដើម្បីរាយការណ៍អំពីការក្លែងបន្លំនោះ។ មិនគិតថ្លៃក្នុងការធ្វើបច្ចុប្បន្នភាពព័ត៌មានទំនាក់ទំនងរបស់អ្នកទេ ហើយក្រសួងសេវាមនុស្សជាតិ (DHS) និងបុគ្គលិក HSRI មិនគួរសួររកលេខសម្ងាត់ ឬពាក្យសម្ងាត់របស់អ្នកឡើយ។ ប្រសិនបើយើងត្រូវការទាក់ទងអ្នក អ្នកអាចទទួលបានការហៅទូរសព្ទពី DHS តាមរយៈលេខ 1-855-697-4347 ឬ HSRI។ លេខសម្គាល់អ្នកហៅចូលជាធម្មតាបង្ហាញ HealthSource RI ជាព័ត៌មានអ្នកហៅចូល។ សារជាអក្សរនឹងទទួលបានមកពី 71536។

## អ្វីដែលអ្នកត្រូវដឹងអំពីការបន្តនៃ MEDICAID របស់អ្នក

### របៀបស្វែងរកកាលបរិច្ឆេទបន្តរបស់អ្នក

ស្វែងរកកាលបរិច្ឆេទបន្ត Medicaid ដែលបានរំពឹងទុករបស់អ្នក ដោយឡុកចូលទៅកាន់គណនីរបស់អ្នកតាមរយៈ www.healthyrhode.ri.gov។ "My Renewal Information" (ព័ត៌មានបន្តរបស់ខ្ញុំ) នឹងត្រូវបានបង្ហាញនៅពេលអ្នកឡុកចូល។

### របៀបដែលយើងនឹងជូនដំណឹងដល់អ្នកថាវាដល់ពេលដែលត្រូវបន្តហើយ

នៅពេលដែលអ្នកទទួលបាន "Recertification/Renewal Notice" (សេចក្ដីជូនដំណឹងអំពីការបញ្ជាក់ឡើងវិញ/ការបន្ត) ពណ៌លឿងពេលខ្លះ នៅចន្លោះពីថ្ងៃទី 1 ខែមេសា ឆ្នាំ 2023 ដល់ថ្ងៃទី 31 ខែមីនា ឆ្នាំ 2024 វាដល់ពេលវេលាដែលអ្នកត្រូវបន្តហើយ។ នៅខាងក្រោមចំណងជើង សេចក្ដីជូនដំណឹងពណ៌លឿងរបស់អ្នកនឹងនិយាយថា៖

1. "មនុស្សដែលបានរាយបញ្ជីខាងក្រោមនឹងត្រូវបានបន្តដោយស្វ័យប្រវត្តិសម្រាប់ Medicaid"។
    - ប្រសិនបើសេចក្តីជូនដំណឹងរបស់អ្នកបង្ហាញដូច្នេះ សូមពិនិត្យមើលព័ត៌មានអំពីសេចក្តីជូនដំណឹង ហើយប្រាប់យើងខ្ញុំ ប្រសិនបើមានការកែប្រែ ឬកំហុស។

    -ឬ-

2. "បុគ្គលដែលបានរាយបញ្ជីខាងក្រោមមានសិទ្ធិទទួលបានការបន្ត Medicaid។ បុគ្គលមួយចំនួនក្នុងចំណោមបុគ្គលទាំងនេះប្រហែលជាលែងត្រូវបានបន្តដោយស្វ័យប្រវត្តិសម្រាប់ Medicaid ដោយផ្អែកលើព័ត៌មានបច្ចុប្បន្ននៅក្នុងគណនីរបស់អ្នកទៀតហើយ"។
    - ប្រសិនបើសេចក្តីជូនដំណឹងរបស់អ្នកបង្ហាញដូច្នេះ អ្នកនឹងទទួលបានសេចក្តីជូនដំណឹងអំពី "តម្រូវការឯកសារបន្ថែម" ឆាប់ៗនេះ។ នៅពេលអ្នកទទួលបានសេចក្តីជូនដំណឹងនេះ សូមប្រមូលឯកសារដែលត្រូវការ ហើយផ្តល់ឯកសារទាំងនោះមកយើងខ្ញុំមុនកាលបរិច្ឆេទកំណត់ដែលបានបង្ហាញនៅលើសេចក្តីជូនដំណឹង។
    - នៅពេលដែលកាលបរិច្ឆេទកំណត់របស់អ្នកកាន់តែខិតជិត យើងនឹងផ្ញើការរំលឹកឱ្យអ្នក ដើម្បីដាក់បញ្ជូនព័ត៌មានរបស់អ្នក ប្រសិនបើយើងមិនបានទទួលវាទេ។

## អ្វីដែលអ្នកត្រូវដឹងអំពីកាលៈទេសៈពិសេស

ដំណើរការបន្តសិទ្ធិទទួលបាន Medicaid នឹងមានភាពខុសប្លែកគ្នាសម្រាប់មនុស្សមួយចំនួនដែលមានកាលៈទេសៈពិសេសដែលប៉ះពាល់ដល់សិទ្ធិទទួលបានរបស់ពួកគេ។ ប្រសិនបើយើងដឹងថាអ្នកជាផ្នែកមួយនៃក្រុមនេះ អ្នកនឹងមិនទទួលបានសេចក្តីជូនដំណឹងពណ៌លឿងទេ។ អ្នកនឹងទទួលបានសេចក្តីជូនដំណឹង "Special Circumstance" (កាលៈទេសៈពិសេស) ពណ៌បៃតង ដែលប្រាប់អ្នកពីអ្វីដែលអ្នកគួរធ្វើ។

ប្រសិនបើអ្នកបានជ្រើសរើសចេញពីការទទួលឯកសារតាមប្រៃសណីយ៍ អ្នកអាចអានសេចក្តីជូនដំណឹងរបស់អ្នកទាំងអស់នៅក្នុងគណនីអនឡាញរបស់អ្នកតាមរយៈwww.healthyrhode.ri.gov។

## របៀបដាក់បញ្ជូនឯកសារដែលត្រូវការ

អ្នកអាចដាក់បញ្ជូនឯកសារដែលត្រូវការមួយចំនួនដោយឡុកចូលទៅក្នុងគណនីរបស់អ្នកតាមរយៈ www.healthyrhode.ri.gov ឬដោយប្រើកម្មវិធីរបស់ HealthyRhode។

ដើម្បីដាក់បញ្ជូនទម្រង់បែបបទនៃការបន្ត Medicaid ដែលបានចុះហត្ថលេខារបស់អ្នក រួមជាមួយនឹងឯកសារដែលបានស្នើសុំផ្សេងទៀត អ្នកអាច៖

- ចូលមើលមជ្ឈមណ្ឌលស្កេនរបស់ RI DHS តាមរយៈអាសយដ្ឋាន 1 Reservoir Ave. ក្នុង Providence ចន្លោះពីម៉ោង 8:30 ព្រឹក ដល់ម៉ោង 4 រសៀល ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ (លើកលែងតែថ្ងៃឈប់សម្រាក)។ យកឯកសាររបស់អ្នកមកជាមួយ ដើម្បីឱ្យបុគ្គលិករបស់យើងអាចស្កេនវាចូលក្នុងប្រព័ន្ធរបស់យើង។
- ឯកសារសំបុត្រ (សូមផ្ញើតែច្បាប់ចម្លង និងរក្សាទុកឯកសារដើមដោយខ្លួនឯង) ទៅកាន់
  P.O. Box 8709, Cranston, Rhode Island 02920-8787

នៅពេលដែលអ្នកបានបញ្ជូនព័ត៌មានរបស់អ្នកដោយជោគជ័យ យើងនឹងផ្ញើជូនអ្នកនូវសេចក្តីជូនដំណឹងអំពីការអរគុណ។ នោះមានន័យថា យើងបានទទួលព័ត៌មានរបស់អ្នក ហើយយើងកំពុងពិនិត្យមើលវា។

## របៀបដែលយើងនឹងជូនដំណឹងដល់អ្នកអំពីស្ថានភាពធានារ៉ាប់រងរបស់អ្នក

នៅពេលដែលយើងបានដំណើរការការបន្តរបស់អ្នក អ្នកនឹងទទួលបាន "សេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចលើអត្ថប្រយោជន៍"។ សេចក្តីជូនដំណឹងនេះនឹងប្រាប់អ្នកថាតើការធានារ៉ាប់រង Medicaid របស់អ្នកត្រូវបានយល់ព្រម ឬបដិសេធ។ ប្រសិនបើអ្នកទទួលបានការបដិសេធសម្រាប់ការធានារ៉ាប់រង សេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចលើអត្ថប្រយោជន៍របស់អ្នកនឹងប្រាប់អ្នកអំពីជម្រើសផ្សេងទៀតសម្រាប់ការបន្តការធានារ៉ាប់រង។

- ប្រសិនបើអ្នកមានសិទ្ធិទទួលបានគម្រោង HealthSource RI ដែលរដ្ឋបង់ប្រាក់ជូនសម្រាប់រយៈពេលពីរខែ សេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចលើអត្ថប្រយោជន៍របស់អ្នកនឹងរួមបញ្ចូលវា។
- ប្រសិនបើអ្នកមិនយល់ស្របនឹងសេចក្តីសម្រេចរបស់យើងអំពីអត្ថប្រយោជន៍របស់អ្នកទេ អ្នកអាចប្តឹងឧទ្ធរណ៍ដោយអនុវត្តតាមដំណើរការដែលបានពិពណ៌នានៅក្នុងសេចក្តីជូនដំណឹងអំពីសេក្តីសម្រេចលើអត្ថប្រយោជន៍របស់អ្នក។

ចូលមើល www.staycovered.ri.gov ដើម្បីស្វែងយល់បន្ថែមអំពីការបន្ត Medicaid និងរបៀបស្វែងរកជំនួយ។